# មេរៀនទី ៩៦៖ ព្រះឆ្លើយតបការអធិស្ឋានរបស់ហាណា

## ១ សាំយូអែល ១៖១-២៨

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/kpGeQiwEii4

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/DQQPXgmkSWQ

**គោលបំណង៖** ព្រះឆ្លើយតបការអធិស្ឋាន។

**ខគម្ពីរចងចាំ៖** ម៉ាថាយ ៧៖៧ *"ចូរសូម នោះតែងនឹងឲ្យមកអ្នក ចូររក នោះតែងនឹងឃើញ ចូរគោះ នោះតែងនឹងបើកឲ្យអ្នក។"*

**ចំរៀង** ( *យូធូបលីង* )៖
១. ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/aasilZXGorc
២. ព្រះចាត់បុត្រា https://youtu.be/eDsWfEtrnS0
៣. ទ្រង់មិនដែលខាន https://youtu.be/uVqBqBENPi4

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«លេងអ៊ូ»**



១. ចែកកុមារជាពីរក្រុមស្មើគ្នា ហើយគូរបន្ទាត់នៅចំកណ្តាល
២. ក្រុមនីមួយៗ ត្រូវរើសមេក្រុមម្នាក់មកប៉ាវ។ បើក្រុមណាឈ្នះ គេត្រូវអ៊ូមុន ហើយរត់ទៅប៉ះកូនក្រុមមួយទៀតឲ្យបាន ត្រូវអ៊ូកុំឲ្យដាច់ដង្ហើម ហើយរត់មកខាងយើងវិញ តែបើកូនក្រុមគេចាប់បាន ហើយដាច់ដង្ហើមនៅកន្លែងគេ ត្រូវនៅទីនោះរងចាំខាងយើងអ៊ូទៅជួយ។
៣. បន្ទាប់មកក្រុមម្ខាងទៀតត្រូវអ៊ូម្តង ហើយបើមានសមាជិកក្រុមជាប់ត្រូវអ៊ូទៅជួយ តែបើគេចាប់ជាប់ត្រូវជាប់ទាំងពីររងចាំគេអ៊ូមកជួយ។
៤. ពេលលេងល្បែងនេះចប់ បើសិនក្រុមណាមានសមាជិកច្រើនជាងគេនឹងឈ្នះល្បែងនេះ។
៥. បន្ទាប់ពីលែងល្បែងនេះចប់ សូមសួរកុមារថា តើវាមានការពិបាកទេក្នុងការរក្សាដង្ហើមឲ្យជាប់ ដើម្បីនិយាយអ៊ូ។ សូមពន្យល់កុមារថា ការអធិស្ឋានគឺដូចដង្ហើមរបស់គ្រីស្ទបរិស័ទអីចឹង ដូច្នេះយើងត្រូវតែរក្សាការអធិស្ឋានឲ្យជាប់ជានិច្ច ដើម្បីរក្សាទំនាក់ទំនងយើងជាមួយព្រះ។

**៤. ការណែនាំមេរៀន**

មុនពេលប្អូនៗទៅរៀនតើប្អូនធ្វើអ្វីចំពោះប៉ាម៉ាក់ប្អូន? ចាស គឺប្អូនៗសុំលុយឪពុកម្តាយមុនទៅសាលា។ ចុះបើសុំមិនបានតើប្អូននឹងធ្វើដូចម្តេច? អ្នកខ្លះយំ អ្នកខ្លះយំស្រែកខ្លាំងៗ អ្នកខ្លះទៀត ដេកដី អ្នកខ្លះទៀត សុំម្តាយមិនឲ្យសុំពុក សុំយាយតា ដើម្បីឲ្យបានលុយទៅរៀន។ អ្នកគ្រូចង់ប្រាប់ប្អូនៗថា មានស្ត្រីម្នាក់ បានអធិស្ឋាន ទាំងយំអណ្តើតអណ្តកសុំកូនពីព្រះដោយការអធិស្ឋាន។ ការអធិស្ឋានគឺជាការដែលយើងនិយាយទៅកាន់ព្រះ។ ថ្ងៃនេះយើងនឹងរៀនពីស្ត្រីម្នាក់នៅក្នុងព្រះគម្ពីរ ដែលនៅពេលដែលគាត់

អធិស្ឋានព្រះទ្រង់បានឆ្លើយតប។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីរបានប្រាប់យើងពីស្ត្រីម្នាក់ដែលមានឈ្មោះថា ហាណា។ នាងបានរៀបការជាមួយបុរសម្នាក់ដែលមានឈ្មោះថា អែលកាណា ហើយគាត់ពិតជាស្រលាញ់នាងខ្លាំងណាស់។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ វាគឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ស្ត្រី ដែលទើបនឹងរៀបការរួចត្រូវមានកូននោះ។ ប៉ុន្តែតាមរយៈការអធិស្ឋានរបស់ហាណាទៅកាន់ព្រះជាម្ចាស់ ទ្រង់មិនបានឆ្លើយតប ក្នុងការដែលឲ្យនាងមានកូននោះទេ។ នាងគឺពិតជាក្រៀមក្រំខ្លាំងណាស់ ដែលព្រះមិនបានឆ្លើយតបនឹងការអធិស្ឋានរបស់នាងយ៉ាងដូច្នេះ។

ជារៀងរាល់ឆ្នាំក្រុមគ្រួសាររបស់លោក អែលកាណាតែងតែឡើងទៅទីសក្ការៈស៊ីឡូរ ដើម្បីថ្វាយយញ្ញបូជា និងលាបំណន់ចំពោះព្រះជាម្ចាស់។ ហើយនៅពេលនោះលោក អេលីគឺជាសង្ឃ។ នៅពេលដែលហាណាបានទៅអធិស្ឋាន នាងក៏បានទូលសូមកូនពីព្រះជាម្ចាស់ម្តងទៀត ហើយនាងបានសន្យាថាប្រសិនបើព្រះប្រទានកូនឲ្យដល់នាង នោះនាងនឹងឲ្យកូននោះបម្រើទ្រង់ពេញមួយជីវិតរបស់គេ។ នាងគឺពិតជាខំប្រឹងខ្លាំងមែនទែនក្នុងការអធិស្ឋាន ទើបធ្វើឲ្យសង្ឃអេលីគិតថា នាងស្រវឹងស្រា! នៅពេលដែលអេលីបានដឹងពីរឿងរ៉ាវរបស់នាង គាត់បានឲ្យនាងត្រឡប់ទៅផ្ទះវិញ ដោយឲ្យនាងមានសេចក្តីសុខសាន្ត និងមានជំនឿលើព្រះជាម្ចាស់ចុះ។

តើអ្នកគិតថាព្រះនឹងឆ្លើយតបការអធិស្ឋានរបស់នាងដែរឬទេ? ប្រាកដណាស់! នាងក៏ចាប់ផ្តើមមានផ្ទៃពោះ ហើយសម្រាលបានកូនប្រុសម្នាក់ដោយដាក់ឈ្មោះថា សាំយូអែល។ ដោយសារតែនាងបានសន្យាថា នឹងថ្វាយកូននោះដល់ទ្រង់ ដោយឲ្យគេបម្រើព្រះអង្គពេញមួយជីវិតរបស់គេ នៅពេលដែល សាំយូអែលធំល្មម នាងបាននាំគេទៅនៅជាមួយសង្ឃ អេលី។ សាំយូអែលក៏រស់នៅជាមួយសង្ឃអេលី នៅក្នុងព្រះវិហាររបស់ព្រះចាប់តាំងពីពេលនោះមក។

តាមរយៈសាច់រឿងរបស់ហាណាបានបង្ហាញថា ព្រះតែងតែឆ្លើយតបការអធិស្ឋានរបស់យើង ប៉ុន្តែពេលខ្លះយើងត្រូវតែបន្តការអធិស្ឋាន និងរងចាំការឆ្លើយតបរបស់ព្រះ។ យើងមិនដឹងថា ព្រះនឹងឆ្លើយតបយើងដោយរបៀបណា ឬពេលណានោះទេ។ សូមកុំបាក់ទឹកចិត្ត ប្រសិនបើព្រះមិនទាន់ឆ្លើយតបនឹងការអធិស្ឋានរបស់អ្នក។ ប្រហែលជាព្រះនឹងឆ្លើយថា ទេ ឬក៏ទ្រង់ឆ្លើយថា ចាំសិន។ សូមកុំបោះបង់ឲ្យសោះ នៅពេលដែលអ្នកអធិស្ឋាន ហើយព្រះមិនឆ្លើយតបជាមួយនឹងការអធិស្ឋានរបស់អ្នកភ្លាមៗនោះ។ ព្រះតែងតែមានផែនការអស្ចារ្យបំផុតសម្រាប់ពួកយើង។ ព្រះស្រលាញ់ពួកយើង ហើយទ្រង់ចង់ពង្រឹងសេចក្តីជំនឿរបស់ពួកយើងផងដែរ។ ព្រះចង់ឲ្យយើងទុកចិត្តទ្រង់។ ហើយព្រះគម្ពីរបានបញ្ជាក់ប្រាប់យើងថា ព្រះតែងតែឆ្លើយតបការអធិស្ឋានរបស់យើងជានិច្ច។

## ៦. សំនួរពិភាក្សា

១. តើហាណាអធិស្ឋានចង់បានអ្វី? *(នាងចង់បានកូន)*

២. តើព្រះបានឆ្លើយតបការអធិស្ឋានរបស់នាងភ្លាមៗដែរឬទេ? *(ទេគឺនាងត្រូវរងចាំ)*

៣. តើអ្នកគិតថាហេតុអ្វីបានជាព្រះមិនឆ្លើយតបនឹងការអធិស្ឋានរបស់យើងភ្លាមៗនោះ?
*(ព្រះតែងតែមានផែនការអស្ចារ្យបំផុតសម្រាប់ពួកយើង។ យើងត្រូវទុកចិត្តថា ព្រះទ្រង់ជ្រាបពីពេលវេលាដ៏ល្អបំផុត សម្រាប់យើងដើម្បីឆ្លើយតបនឹងការអធិស្ឋានរបស់យើង)*
៤.តើហាណាបានសន្យាដូចម្តេចចំពោះព្រះជាម្ចាស់ ប្រសិនទ្រង់ឆ្លើយតបការអធិស្ឋានរបស់នាង?

*(នាងបានសន្យាថា នឹងឲ្យកូនប្រុសរបស់នាងទៅព្រះ ហើយឲ្យគេរស់នៅបម្រើទ្រង់)*
៥. តើអ្នកគិតថា ការក្សាការសន្យាជាមួយព្រះតាមរយៈការអធិស្ឋានសំខាន់ដែរឬទេ?
*(ត្រូវហើយ វាពិតជាសំខាន់ខ្លាំងណាស់!)*

**៧. ល្បែងកំសាន្ត "អធិស្ឋាន" "រាំសរសើរតម្កើងព្រះ" "អរព្រះគុណ" ឬក៏ "សើច"**

សម្ភារៈដែលត្រូវការ៖ ក្រដាស A4 ៤សន្លឹក ដែលសរសេរពាក្យថា "អធិស្ឋាន" "រាំសរសើរតម្កើងព្រះ" "អរព្រះគុណ" "សើច" និងតុ




១. គ្រូត្រូវបិតក្រដាសទាំង៤ សន្លឹកនៅលើជញ្ជាំង ត្រង់ទីតាំងខុសៗគ្នា (មិនឲ្យកុមារឃើញពាក្យខាងក្នុងទេ)។
២. កុមារត្រូវរាំនៅជុំវិញតុ (ឬកៅអី) ដោយចាក់ភ្លេង ហើយនៅពេលភ្លេងឈប់កុមារត្រូវរត់ទៅកាន់ជញ្ជាំង ដែលគេបានជ្រើសរើសនោះ។
៣. កុមារត្រូវតែធ្វើតាមពាក្យដែលបានបិតនោះ។ ឧទាហរណ៍៖ ប្រសិន បើគេរត់ទៅរកជញ្ជាំងដែលបិតពាក្យថា "អធិស្ឋាន" ពួកគេត្រូវអធិស្ឋាន។ ហើយប្រសិនបើពួកគេរត់ទៅរកជញ្ជាំងដែលមានពាក្យថា "រាំ" ពួកគេត្រូវរាំ
៤. ឲ្យពេលកុមារ ១ នាទី ហើយបន្តលេងល្បែងនោះ។
៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ព្រះតែងតែឆ្លើយតបជាមួយនឹងការអធិស្ឋានរបស់យើង ទោះបីជាពេលខ្លះយើងត្រូវធ្វើការរងចាំក៏ដោយ។ សូមចាំថា ទោះបីជាព្រះឆ្លើយថា "ទេ" ក៏ដោយក៏ជាចម្លើយរបស់ទ្រង់ដែរ។ យើងត្រូវតែ ទុកចិត្តព្រះ ហើយស្តាប់បង្គាប់ទ្រង់ជានិច្ច។

**៨. ខគម្ពីរចងចាំ**

**ម៉ាថាយ ៧៖៧** *"ចូរសូម នោះតែងនឹងឲ្យមកអ្នក ចូររក នោះតែងនឹងឃើញ ចូរគោះ នោះតែងនឹងបើកឲ្យអ្នក។"*

**៩. ហត្ថកម្ម «ខ្ញុំអធិស្ឋានសម្រាប់អ្នក»**

សម្ភារៈដែលត្រូវការ៖ កន្ត្រៃ កូល័រ និង បោះពុម្ពបាតដៃអធិស្ឋាន(ទំព័រខាងក្រោម)



១. សូមកាត់បាតដៃអធិស្ឋានចេញមកហើយតុបតែងវា។
២. ប្រាប់កុមារឲ្យជ្រើសរើសនរណាម្នាក់ ដែលគេចង់ឲ្យក្រដាសនេះ។ អាចជានរណាម្នាក់ដែលគេចង់អធិស្ឋានឲ្យ។
៣. នៅចំកណ្តាលបាតដៃសូមគូសរូបបេះដូង ហើយសរសេរប្រយោគមួយ។ កុមារអាចសរសេរថា "ខ្ញុំអធិស្ឋានឲ្យអ្នកមានសុខភាពល្អ" ឬ "ខ្ញុំសូមអធិស្ឋានឲ្យអ្នកមានសុភមង្គល" ឬក៏ "ខ្ញុំសូមអធិស្ឋានឲ្យអ្នក ទទួលបានការសង្គ្រោះ" ។
៤. សូមលើកទឹកចិត្តឲ្យកុមារប្រគល់ក្រដាសនេះទៅកាន់មនុស្សពិសេសរបស់ពួកគេ។
៥. សូមរំលឹកកុមារថា ព្រះទ្រង់តែងតែឆ្លើយតបការអធិស្ឋានរបស់ពួកយើងជានិច្ច។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖** (**សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន**)

ពួកយើងទាំងអស់គ្នាសុទ្ធតែមានបទពិសោធន៍ពីការឈឺចាប់ និងក្រៀមក្រំ ហើយព្រះយេស៊ូវទ្រង់ក៏ធ្លាប់ទទួលនូវបទពិសោធន៍ទាំងអស់នោះដែរ។ យើងតែងតែអាចដឹងបានថា ព្រះទ្រង់គង់ទីនេះ ជាមួយយើងតែងតែស្តាប់ ហើយឆ្លើយតបនូវការអធិស្ឋានរបស់យើង។ សូមអានព្រះគម្ពីរ **១ សាំយូអែល ១៖១-២០** សារឡើងវិញ។ តើព្រះនឹងឆ្លើយតបជាមួយយើងយ៉ាងដូចម្តេច ប្រសិនបើយើងស្រែកអង្វរទៅកាន់ទ្រង់ទាំងទុក្ខព្រួយ និងឈឺចាប់នោះ? សេចក្តីក្រៀមក្រំ ការឈឺចាប់ ទុក្ខព្រួយ តើអ្នកគួរតែថ្វាយការនោះ ទៅកាន់ព្រះដែរឬទេ? វាគឺជាការអស្ចារ្យមែនទែន ដែលយើងអាចបម្រើព្រះ ដែលទ្រង់តែងតែខ្វាយខ្វល់ពីការឈឺចាប់របស់មនុស្សនោះ។ សូមងាកបែរទៅរកព្រះ ហើយផ្ទេររាល់ទាំងការឈឺចាប់របស់យើងទៅកាន់ទ្រង់។

# ខ្ញុំអធិស្ឋានសម្រាប់អ្នក



# ខ្ញុំអធិស្ឋានសម្រាប់អ្នក

